រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ : ០០៤ សរណន .

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីណែនាំ

## ស្តីពី

## ការរៀបចំបែបបទស្នើសុំបណ្ណសរសើរ និង គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

ដើម្បីជាគោលនយោបាយលើកទឹកចិត្ត និង ចារឹកទុកនូវស្នាដៃ គុណបំណាច់របស់មន្ត្រីរាជការស្ថិតក្នុងក្របខ័ណ្ឌមន្ត្រីរដ្ឋបាលស៊ីវិល ក្រសួងមហាផ្ទៃ ដែលបានខិតខំតស៊ូ ពុះពារ ក្នុងការបំពេញការងារ តាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល អោយបានសំរេចគ្រប់បែបយ៉ាងគួរជាទីមោទនៈ ក្នុងបុព្វហេតុ កសាង ស្តារ និង អភិវឌ្ឍន៍ប្រទេសជាតិ និង ដើម្បីអោយដំណើរការ ជ្រើសរើសមន្ត្រីរាជការ ដែលមានស្នាដៃឆ្នើមក្នុងការងារប្រកបដោយគតិយុត្តិធម៌ ស្មើភាព និង ត្រឹមត្រូវស្របតាមសារាចរណែនាំរបស់រាជរដ្ឋាភិបាលលេខ ០១ ស.រ.ណ.ន ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០០១ ស្តីពីការរៀបចំបែបបទស្នើសុំគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា ក្រសួងមហាផ្ទៃ សូមកំណត់ក្នុងការលើកសរសើរដល់មន្ត្រីរាជការក្រោមឱវាទ តាមរូបភាពពីរយ៉ាង មានខ្លឹមសារណែនាំ ដូចខាងក្រោម :

### I-<u>ការផ្តល់បណ្ណសរសើរ និង ការស្នើសុំគ្រឿងឥស្សរិយយស</u> :

បណ្ណសរសើរ និង គ្រឿងឥស្សរិយយស ត្រូវបានផ្តល់ និង បំពាក់ជូនមន្ត្រីរាជការម្នាក់ៗ ដែលមានស្នាដៃឆ្នើមក្នុងការងារជារៀងរាល់ ០២ ឆ្នាំម្តង ដោយឆ្លាស់វេនគ្នា ។

#### ១-<u>បណ្ណសរសើរ</u> :

បណ្ណសរសើរជារូបភាពសរសើរដល់មន្ត្រីរាជការ ដែលមានស្នាដៃឆ្នើម ចេញដោយក្រសួងមហាផ្ទៃ ។ អ្នករាជការទាំងឡាយណា ដែលទទួលបាននិទ្ទេសល្អ មានពិន្ទុចាប់ពី ១៥ ដល់ក្រោម ១៧ ពិន្ទុ ត្រូវទទួលបណ្ណសរសើរ ។

២៦០

គ្រប់ខេត្ត ក្រុង និង គ្រប់អង្គភាពចំណុះទីស្តីការការក្រសួង អាចស្នើសុំប័ណ្ណសរសើរ សំរាប់ផ្តល់ជូនមន្ត្រីរាជការក្រោមឱវាទ ដែលមានស្នាដៃឆ្នើមនៅក្នុងខេត្ត ក្រុង និង អង្គភាពចំណុះទីស្តីការក្រសួងបាន មិនឱ្យលើសពី ១០ % នៃចំនួនក្របខ័ណ្ឌសរុបរបស់ខេត្ត ក្រុង និង អង្គភាពនីមួយៗឡើយ ។ ក្នុងចំនួនសមាមាត្រ ១០ % នេះ ត្រូវបានជ្រើសរើសមន្ត្រីពីក្នុងក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ០២% ក្របខ័ណ្ឌមន្ត្រីក្រមការ ០៣% ក្របខ័ណ្ឌលេខាធិការរដ្ឋបាល ក្របខ័ណ្ឌអនុរក្សពន្ធនាគារ ០៤ % និង ក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល ០១ % ។

២- **គ្រឿងឥស្សរិយយស** :

គ្រឿងឥស្សរិយយស ជារូបភាពលើកសរសើរ សំរាប់បំពាក់ជូនមន្ត្រីរាជការ ដែលមានស្នាដៃឆ្នើមបំផុត ដែលក្រសួងមានភារកិច្ចពិនិត្យ ជ្រើសរើស និងស្នើសុំការសំរេចពីរាជរដ្ឋាភិបាល ។

អ្នករាជការទាំងឡាយណា ដែលទទួលបានពិន្ទុចាប់ពីនិទ្ទេសល្អឡើងទៅ (ពិន្ទុចាប់ពី ១៧ ដល់ ២០ពិន្ទុ) ត្រូវបានស្នើសុំបំពាក់គ្រឿងឥស្សរិយយសដូចខាងក្រោម :

- ពិន្ទុចាប់ពី ១៧ ដល់ក្រោម ១៨ពិន្ទុ សំរាប់មេដាយការងារថ្នាក់សំរិទ្ធ
- ពិន្ទុចាប់ពី ១៨ ដល់ក្រោម ១៩ ពិន្ទុ សំរាប់មេដាយការងារថ្នាក់ប្រាក់
- ពិន្ទុចាប់ពី ១៩ ដល់ ២០ ពិន្ទុ សំរាប់មេដាយការងារថ្នាក់មាស

គ្រប់ខេត្ត ក្រុង និង គ្រប់អង្គភាពចំណុះទីស្តីការក្រសួង អាចស្នើសុំគ្រឿងឥស្សរិយយស បំពាក់ជូនជនគំរូ ដែលមានស្នាដៃឆ្នើមបំផុត នៅក្នុងខេត្ត ក្រុង និង អង្គភាពចំណុះទីស្តីការក្រសួងបាន មិនអោយលើសពី ១០% នៃចំនួនក្របខ័ណ្ឌសរុបរបស់ខេត្ត ក្រុង និង អង្គភាពឡើយ ។ ក្នុងចំនួនសមាមាត្រ ១០% នេះ ត្រូវបានបែងចែកជ្រើសរើសពីក្នុង :

- ក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ០២%
- ក្របខ័ណ្ឌមន្ត្រីក្រមការ ០៣%
- ក្របខ័ណ្ឌលេខាធិការរដ្ឋបាល ក្របខ័ណ្ឌអនុរក្សពន្ធនាគារ ០៤% និង
- ក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល ០១%

ចំនួនបេក្ខជនដែលបានស្នើសុំគ្រឿងឥស្សរិយយស ក្នុងលំដាប់ឋានានុក្រមខ្ពស់ ត្រូវអោយតិចជាងចំនួនបេក្ខជន ដែលស្នើសុំគ្រឿងឥស្សរិយយស ក្នុងលំដាប់ឋានានុក្រមទាបជាង ។

## II- **បែបបទនៃការជ្រើសរើស និង ដាក់មូលវិចារណ៍**

### ១- **កាលបរិច្ឆេទនៃការជ្រើសរើស**

នៅរៀងរាល់ខែសីហា នៃឆ្នាំនីមួយៗ ប្រធានអង្គភាពគ្រប់ថ្នាក់ ត្រូវដំណើរការប្រជុំជ្រើសរើសមន្ត្រី

រាជការ ដែលមានស្នាដៃឆ្នើមនៅក្នុងអង្គភាពរបស់ខ្លួន ដើម្បីធ្វើការលើកសរសើរ ផ្អែកតាមព្រឹត្តិប័ត្រវាយតម្លៃវិជ្ជាជីវៈរបស់មន្ត្រីរាជការ សំរាប់លើកសរសើរ ដែលសាមីខ្លួនបានបំពេញរួចហើយ ។

២- **របៀបដាក់មូលវិចារណ៍**

ប្រធានអង្គភាពនីមួយៗ ត្រូវបូកសរុបពិន្ទុនៅគ្រប់ចំណុចទាំងអស់ ដែលមានចែងក្នុងតារាងវាយតម្លៃរបស់មន្ត្រីម្នាក់ៗ ក្នុងលក្ខណៈវិនិច្ឆ័យខាងក្រោម ដើម្បីរកពិន្ទុសរុបមួយ ដែលជាមូលដ្ឋានក្នុងការដាក់មូលវិចារណ៍។

ពិន្ទុសរុបគ្រប់ចំនួនទាំងអស់គឺ ២០ ពិន្ទុ ។

ការដាក់មូលវិចារណ៍ត្រូវផ្អែកលើចំណុចដូចខាងក្រោម :

- បើបាន ២០ ពិន្ទុ ត្រូវបញ្ជាក់ថា បាននិទ្ទេស : ប្រសើរណាស់
- បើបាន ១៩ ពិន្ទុ ដល់ក្រោម ២០ ពិន្ទុ ត្រូវបញ្ជាក់ថា បាននិទ្ទេស : ល្អណាស់
- បើបាន ១៦ ពិន្ទុ ដល់ក្រោម ១៩ ពិន្ទុ ត្រូវបញ្ជាក់ថា បាននិទ្ទេស : ល្អ
- បើបាន ១៣ ពិន្ទុ ដល់ក្រោម ១៦ ពិន្ទុ ត្រូវបញ្ជាក់ថា បាននិទ្ទេស : បង្គួរ
- បើបាន ១០ ពិន្ទុ ដល់ក្រោម ១៣ ពិន្ទុ ត្រូវបញ្ជាក់ថា បាននិទ្ទេស : មធ្យម
- បើបាន 0 ពិន្ទុ ដល់ក្រោម ១០ ពិន្ទុ ត្រូវបញ្ជាក់ថា បាននិទ្ទេស : ខ្សោយ

## III- លក្ខណៈវិនិច្ឆ័យដាក់ពិន្ទុ

ដោយអនុឡោមទៅតាមសារាចរណែនាំ របស់រាជរដ្ឋាភិបាលលេខ ០១ សរណន ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០០១ ស្តីពីការរៀបចំបែបបទស្នើសុំគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា ការកំណត់លក្ខណៈវិនិច្ឆ័យ ដាក់ពិន្ទុ ដែលជាមូលដ្ឋានក្នុងការជ្រើសរើសមន្ត្រីរាជការ ដែលមានស្នាដៃឆ្នើម សំរាប់លើកសរសើររៀងរាល់ពីរឆ្នាំម្តង ត្រូវផ្អែកលើលក្ខណៈសម្បត្តិធំៗ ០៥ យ៉ាងដូចខាងក្រោម :

**១-មានសីលធម៌រស់នៅស្អាតស្អំ មិនប្រព្រឹត្តិអំពើពុករលួយ និង សកម្មភាពផ្ទុយពីច្បាប់រដ្ឋ**

**ក- អាកប្បកិរិយា** (០១ ពិន្ទុ)

- មន្ត្រីរាជការទាំងឡាយណា មានអាកប្បកិរិយាល្អ ត្រឹមត្រូវ ស្លូតបូត តែម៉ឺងម៉ាត់ក្នុងការងារ ត្រូវបាន ០១ ពិន្ទុ ។

- មន្ត្រីរាជការទាំងឡាយណា មានអាកប្បកិរិយាមិនសូវល្អ មានភាពធូររលុងក្នុងការងារ ត្រូវបាន ១/២ ពិន្ទុ។

- មន្ត្រីរាជការទាំងឡាយណា មានអាកប្បកិរិយាច្រលើសបើស ព្រហើនកោងកាច មានភាពធូររលុងក្នុងការងារ ត្រូវបានពិន្ទុសូន្យ ។

ខ- សីលធម៌ (០១ ពិន្ទុ)

-មន្ត្រីរាជការទាំងឡាយណា ដែលមានសីលធម៌រស់នៅសមរម្យ ស្មោះត្រង់ មិនកេងប្រវ័ញ្ច មិនពុករលួយ មានសាមគ្គីភាពទូលំទូលាយ ត្រូវបាន ០១ ពិន្ទុ ។

-មន្ត្រីរាជការទាំងឡាយណា ដែលមានសីលធម៌រស់នៅមិនសមរម្យ មានភាពមិនស្មោះត្រង់ ប្រព្រឹត្តអំពើកេងប្រវ័ញ្ច ពុករលួយ មានការរំលោភបំពានលើអ្នកដទៃ ឬ លើប្រជារាស្ត្រ សាមគ្គីភាពពុំទូលំទូលាយ ប្រព្រឹត្តអំពើ អបាយមុខខុសនឹងច្បាប់រដ្ឋ ត្រូវបានពិន្ទុសូន្យ ។

**២-គំនិតផ្តួចផ្តើម មនសិការវិជ្ជាជីវៈខ្ពស់ សកម្មការងារ ឧស្សាហ៍ព្យាយាម ច្នៃប្រឌិត និង ទទួលខុសត្រូវ**

**ក- មនសិការវិជ្ជាជីវៈ** (០២ ពិន្ទុ)

-មន្ត្រីរាជការណា ដែលមានមនសិការវិជ្ជាជីវៈខ្ពស់ ត្រូវបាន ០២ ពិន្ទុ ។

-មន្ត្រីរាជការណា ដែលយកម៉ោងរដ្ឋបាល ទៅប្រកបមុខរបរផ្ទាល់ខ្លួន ឬ ប្រកបមុខរបរណា ដែលនាំអោយប៉ះពាល់ដល់កិត្តិយស និង សេចក្តីថ្លៃថ្នូររបស់អ្នករាជការ ត្រូវដក ០១ ពិន្ទុ ។

-មន្ត្រីរាជការណា ដែលបោះពុម្ពផ្សាយ ឬ ធ្វើការផ្សព្វផ្សាយពត៌មាន ដែលមានពាក់ព័ន្ធនៅក្នុងមុខងារក្រសួង ដោយពុំមានការអនុញ្ញាតជាមុន ពីប្រធានស្ថាប័នសាមី ត្រូវបានពិន្ទុសូន្យ ។

**ខ- អព្យាក្រឹតភាព** (០២ ពិន្ទុ)

-មន្ត្រីរាជការណា ដែលមានអព្យាក្រឹតភាពក្នុងសកម្មភាពការងាររដ្ឋបាល ត្រូវបាន ០២ ពិន្ទុ ។

-មន្ត្រីរាជការណា ដែលយក និង ប្រើប្រាស់មុខងាររបស់ខ្លួន និង សំភារៈរបស់រដ្ឋដើម្បីបំរើ សកម្មភាពនយោបាយ ដូចជាធ្វើការដើម្បីផលប្រយោជន៍ដល់បេក្ខជន ឬ គណបក្សនយោបាយណាមួយ ឬ ប្រឆាំងនឹងបេក្ខជន ឬ គណបក្សនយោបាយណាមួយ ។ បើមានកំហុស :

- លើកទី ១ ត្រូវដក ០១ ពិន្ទុ
- លើកទី ២ ត្រូវបានពិន្ទុសូន្យ

**គ- ការគោរពវិន័យ** : (០២ ពិន្ទុ)

-មន្ត្រីរាជការណា គោរពវិន័យល្អ ពុំដែលអវត្តមានដោយគ្មានមូលហេតុ ឬ ដោយគ្មានច្បាប់អនុញ្ញាត ត្រូវបាន ០២ ពិន្ទុ ។

-មន្ត្រីរាជការណា ដែលអវត្តមានដោយគ្មានមូលហេតុ ឬ ដោយគ្មានច្បាប់អនុញ្ញាត :

- ចំនួន ០១ ដង ដល់ ០៣ ដង ក្នុងមួយឆ្នាំ ត្រូវដក ១/២ ពិន្ទុ
- ចំនួន ០៤ ដង ដល់ ០៦ ដង ក្នុងមួយឆ្នាំ ត្រូវដក ០១ ពិន្ទុ

• ចំនួន ០៧ ដងឡើងទៅ ក្នុងមួយឆ្នាំ ត្រូវបានពិន្ទុ សូន្យ

ឃ- **ការចាត់តាំង** (០២ ពិន្ទុ)

-មន្ត្រីរាជការណា ដែលគោរពបទបញ្ជាថ្នាក់លើ ដែលបានចាត់តាំងអោយទៅធ្វើការ ទោះនៅទីតំបន់ណាក៏ដោយ ទាំងក្នុង និង ក្រៅប្រទេស ត្រូវបាន ០២ ពិន្ទុ ។

-មន្ត្រីទាំងឡាយណា ដែលពុំគោរពបទបញ្ជាថ្នាក់លើ ដែលបានចាត់តាំងអោយទៅបំពេញកាងារ :

• ចំនួន ០១ ដង ត្រូវដក ០១ ពិន្ទុ

• ចំនួន ០២ ដង ត្រូវបានពិន្ទុសូន្យ

៣-**សមត្ថភាពបំពេញការងារ** ០៤ (ពិន្ទុ)

-មន្ត្រីរាជការណា ដែលបំពេញការងារបានល្អ សំរេចបាននូវរាល់ភារកិច្ច ដែលបានប្រគល់អោយបានទាន់ពេលវេលា ហ្មត់ចត់ ត្រូវបាន ០៤ ពិន្ទុ ។

-មន្ត្រីរាជការណា ដែលបំពេញការងារសំរេចបាននូវភារកិច្ចដែលបានប្រគល់អោយ តែមានការយឺតយ៉ាវ ត្រូវបាន ០៣ ពិន្ទុ ។

-មន្ត្រីរាជការណាដែលបំពេញការងារបានល្អ សំរេចបានត្រឹមពាក់កណ្តាល ត្រូវបាន ០២ ពិន្ទុ

-មន្ត្រីរាជការណាដែលបំពេញការងារបានល្អ សំរេចបានត្រឹមពាក់កណ្តាល មានការយឺតយ៉ាវ ត្រូវបាន ០១ ពិន្ទុ ។

-មន្ត្រីរាជការទាំងឡាយណាដែលបំពេញការងារមិនបានសំរេច តែសាមីខ្លួនបានខិតខំប្រឹងប្រែងអស់ពីសមត្ថភាពដែរ ត្រូវបាន ១/២ ពិន្ទុ ។

-មន្ត្រីរាជការទាំងឡាយណា ដែលបំពេញការងារពុំបានសំរេច ដោយសារសាមីខ្លួនមានការខ្ជិខ្ជា ពុំបានខិតខំប្រឹងប្រែង ត្រូវបានពិន្ទុសូន្យ ។

៤- **សាមគ្គីភាព និង ទំនាក់ទំនងល្អជាមួយមហាជន**

ក- **ទំនាក់ទំនងជាមួយមន្ត្រីរាជការ** (០២ ពិន្ទុ)

-មន្ត្រីទាំងឡាយណា ដែលមានទំនាក់ទំនង និង សហការការងារជាមួយមន្ត្រីរាជការទាំងក្នុង និង ក្រៅអង្គភាពបានល្អ ត្រូវបាន ០២ ពិន្ទុ ។

-មន្ត្រីរាជការទាំងឡាយណា ដែលមានទំនាក់ទំនង និង សហការការងារជាមួយមន្ត្រីរាជការទាំង ក្នុង និង ក្រៅអង្គភាព ពុំសូវជិតស្និទ្ធ ធ្វើអោយដំណើរការការងារ ពុំសូវមានភាពរលូន ត្រូវបាន ០១ ពិន្ទុ ។

-មន្ត្រីរាជការទាំងឡាយណា ដែលមានទំនាក់ទំនង និង សហការការងារជាមួយមន្ត្រីរាជការ ទាំងក្នុង និង ក្រៅអង្គភាព ពុំបានល្អ ធ្វើអោយរាំងស្ទះដល់ការងារ ត្រូវបានពិន្ទុសូន្យ ។

៤- ទំនាក់ទំនងជាមួយប្រជារាស្ត្រ (០២ ពិន្ទុ)

-មន្ត្រីរាជការណា ដែលមានទំនាក់ទំនងល្អ ជិតស្និទ្ធជាមួយប្រជារាស្ត្រ ក្នុងមូលដ្ឋានដែលខ្លួនគ្រប់គ្រង ត្រូវបាន ០២ ពិន្ទុ ។

-មន្ត្រីរាជការណា ដែលពុំសូវមានទំនាក់ទំនងល្អ ជាមួយប្រជារាស្ត្រ ត្រូវបាន ០១ ពិន្ទុ ។

-មន្ត្រីរាជការណា ដែលពុំមានទំនាក់ទំនងល្អជាមួយប្រជារាស្ត្រ ធ្វើអោយមានការថ្នាំងថ្នាក់ពីសំណាក់ប្រជារាស្ត្រ បាត់ជំនឿលើមន្ត្រីរាជការ ត្រូវបានពិន្ទុសូន្យ ។

៥- មានស្មារតីស្នេហាជាតិ គិតគូរដល់ផលប្រយោជន៍ជាតិ និង កិត្តិយសរបស់ក្រសួង (០២ ពិន្ទុ)

-មន្ត្រីរាជការទាំងឡាយណា ដែលមានស្មារតីស្នេហាជាតិ គិតគូរដល់ផលប្រយោជន៍ជាតិ និង កិត្តិយស របស់ក្រសួង តាមរយៈការជួយឧបត្ថម្ភទាំងកំលាំងកាយ បញ្ញា ឬ សំភារៈដល់ប្រទេសជាតិ ត្រូវបាន ០២ ពិន្ទុ ។

-មន្ត្រីរាជការទាំងឡាយណា ដែលធ្វើឱ្យប៉ះពាល់ដល់កិត្តិយស និង សេចក្តីថ្លៃថ្នូររបស់ប្រទេសជាតិ តាមរយៈសកម្មភាពរបស់ខ្លួន ត្រូវបានពិន្ទុសូន្យ ។

## IV - សមត្ថកិច្ចដាក់ពិន្ទុ និង មូលវិចារណ៍ :

### ១- ទីស្តីការក្រសួង :

-រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានសមត្ថកិច្ចដាក់ពិន្ទុ និង មូលវិចារណ៍ដល់មន្ត្រីរាជការ ដែលកំពុងកាន់មុខតំណែងជា អគ្គនាយក អគ្គាធិការ អគ្គលេខាធិការ អភិបាលគ្រប់ខេត្ត ក្រុង ។

-អគ្គនាយក អគ្គាធិការ អគ្គលេខាធិការ មានសមត្ថកិច្ចដាក់ពិន្ទុ និង មូលវិចារណ៍ ដល់មន្ត្រីរាជការក្រោមឱវាទ ដែលកំពុងកាន់មុខតំណែងជា អគ្គនាយករង អគ្គាធិការរង អគ្គលេខាធិការរង ។ អគ្គនាយក និងអគ្គនាយករង អគ្គលេខាធិការ និង អគ្គលេខាធិការរង អគ្គាធិការ និងអគ្គាធិការរង ត្រូវរួមគ្នាពិនិត្យពិភាក្សាដាក់ពិន្ទុ និងមូលវិចារណ៍ ដល់អធិការ គ្រប់ប្រធាននាយកដ្ឋានក្រោមឱវាទទាំងអស់ ។

-ប្រធាននាយកដ្ឋាននីមួយៗ និងអធិការ មានសមត្ថកិច្ចដាក់ពិន្ទុ និង មូលវិចារណ៍ ដល់អនុប្រធាននាយកដ្ឋាន និងអធិការរង ។ ប្រធាននាយកដ្ឋាននីមួយៗ អធិការ និងអនុប្រធាននាយកដ្ឋាន និងអធិការរង ត្រូវរួមគ្នាពិនិត្យដាក់ពិន្ទុ និងមូលវិចារណ៍ ដល់មន្ត្រីរាជការក្រោមឱវាទទាំងអស់ ដោយមានការបញ្ជាក់ ពីប្រធានអង្គភាពសាមី ។ ដោយឡែកប្រធាននាយកដ្ឋាន និងអនុប្រធាននាយកដ្ឋានពន្ធនាគារ ត្រូវរួមគ្នាពិនិត្យដាក់ពិន្ទុ និងមូលវិចារណ៍ ដល់ប្រធានពន្ធនាគារកណ្តាលផងដែរ ។

២៦៤

-ប្រធានពន្ធនាគារកណ្តាល មានសមត្ថកិច្ចវាយតំលៃ ដាក់ពិន្ទុ និងមូលវិចារណ៍ ដល់អនុប្រធានពន្ធនាគារកណ្តាលក្រោមឱវាទទាំងអស់ ។ ប្រធាន និងអនុប្រធានពន្ធនាគារកណ្តាល ត្រូវរួមគ្នាពិនិត្យពិភាក្សាដាក់ពិន្ទុ និងមូលវិចារណ៍ ដល់មន្ត្រីពន្ធនាគារកណ្តាលក្រោមឱវាទទាំងអស់ ។

២-<u>សាលាខេត្ត ក្រុង</u> :

-ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអភិបាល អភិបាលរងក្រុង អភិបាល អភិបាលរងខេត្ត ក្រុង ត្រូវរួមគ្នាពិនិត្យពិភាក្សាដាក់ពិន្ទុ និងមូលវិចារណ៍ ដល់មន្ត្រីរាជការក្រោមឱវាទរួមមាន : អភិបាលស្រុក ខណ្ឌ ប្រធានអង្គភាពទាំង៤ ចំណុះសាលាខេត្ត ក្រុង (នាយខុទ្ទកាល័យ អគ្គលេខាធិការ នាយក្រុមហិរញ្ញវត្ថុ និងអធិការនៃក្រុមអធិការកិច្ច) និងប្រធានពន្ធនាគារខេត្ត ក្រុង ។

-ប្រធានអង្គភាពនីមួយៗ ចំណុះសាលាខេត្ត ក្រុង មានសមត្ថកិច្ចវាយតំលៃដាក់ពិន្ទុ និងមូលវិចារណ៍ ដល់អនុប្រធានអង្គភាពក្រោមឱវាទ។ ប្រធាន និងអនុប្រធានអង្គភាពនីមួយៗ ត្រូវរួមគ្នាពិនិត្យ ពិភាក្សាវាយតំលៃដាក់ពិន្ទុ និងមូលវិចារណ៍ ដល់មន្ត្រីក្រោមឱវាទទាំងអស់ ដោយមានការឯកភាពពីអភិបាលខេត្ត ក្រុងសាមី ។

-ប្រធានពន្ធនាគារខេត្ត ក្រុង មានសមត្ថកិច្ចវាយតំលៃដាក់ពិន្ទុ និងមូលវិចារណ៍ដល់អនុប្រធានពន្ធនាគារខេត្ត ក្រុងក្រោមឱវាទ ។ ប្រធាន និងអនុប្រធានពន្ធនាគារខេត្ត ក្រុង ត្រូវរួមគ្នាពិនិត្យ ពិភាក្សាវាយតំលៃ ដាក់ពិន្ទុ និងមូលវិចារណ៍ ដល់មន្ត្រីពន្ធនាគារខេត្ត ក្រុងក្រោមឱវាទទាំងអស់ ។

៣-<u>សាលាស្រុក ខណ្ឌ</u> :

-អភិបាលស្រុក ខណ្ឌនីមួយៗ មានសមត្ថកិច្ចវាយតំលៃដាក់ពិន្ទុ និងមូលវិចារណ៍ ដល់អភិបាលរងស្រុក ខណ្ឌ ។ អភិបាល និងអភិបាលរងស្រុក ខណ្ឌ ត្រូវរួមគ្នាពិនិត្យ ពិភាក្សាវាយតំលៃដាក់ពិន្ទុ និងមូលវិចារណ៍ ដល់មន្ត្រីរាជការ ក្រោមឱវាទទាំងអស់ ដោយមានការបញ្ជាក់ឯកភាពពីអភិបាលខេត្ត ក្រុងសាមី ។

## V - <u>អំពីនៃការបញ្ជូនសំណុំបែបបទ</u>

គ្រប់ខេត្ត ក្រុង និងអង្គភាពចំណុះទីស្តីការក្រសួង មានភារកិច្ចបូកសរុប ជ្រើសរើសមន្ត្រីរាជការដែលមានស្នាដៃឆ្នើម ដើម្បីលើកសរសើរតាមរូបភាពទាំងពីរខាងលើ ហើយធ្វើសំណើ និង បញ្ជីឈ្មោះបេក្ខជន (ដូចមានគំរូជូនភ្ជាប់មកជាមួយ) ចំនួន ០២ ច្បាប់ ផ្ញើមកក្រសួងមហាផ្ទៃ (នាយកដ្ឋានបុគ្គលិក និង បណ្តុះបណ្តាលវិជ្ជាជីវៈ) យ៉ាងយូរបំផុតត្រឹមថ្ងៃទី៣១ ខែសីហា នៃឆ្នាំនីមួយៗ ដើម្បីរៀបចំដាក់ជូនគណៈកម្មការពិនិត្យលក្ខណៈសម្បត្តិ រួចហើយក្រសួងពិនិត្យ ជ្រើសរើស និង ធ្វើសំណើទៅរាជរដ្ឋាភិបាលពិនិត្យ សំរេច ។ សំណុំបែបបទទាំងនោះ ត្រូវភ្ជាប់មកជាមួយនូវព្រឹត្តិប័ត្រពិន្ទុ និង មូលវិចារណ៍ ព្រមទាំងរបាយការណ៍ ស្នាដៃ និង គុណបំណាច់របស់បេក្ខជនម្នាក់ៗ (សរសេរដោយដៃបេក្ខជនផ្ទាល់) ។

ព្រឹត្តិប័ត្រពិន្ទុ និង មូលវិចារណ៏ ជាមូលដ្ឋានចំបង ក្នុងការពិនិត្យលក្ខណៈសម្បត្តិមន្ត្រីរាជការ ដើម្បីលើកសំណើសុំផ្តល់ជូនប័ណ្ណសរសើរ និង បំពាក់គ្រឿងឥស្សរិយយសប្រចាំឆ្នាំនីមួយៗ ។

ព្រឹត្តិប័ត្រពិន្ទុ និង មូលវិចារណ៏ មានគំរូជូនភ្ជាប់មកជាមួយស្រាប់ ។

ក្រសួមហាផ្ទៃ សង្ឃឹមយ៉ាងមុតមាំថា ឯកឧត្តម អភិបាលគ្រប់ខេត្ត ក្រុង ប្រធានអង្គភាពចំណុះ ទីស្តីការក្រសួងគ្រប់លំដាប់ថ្នាក់ នឹងចាត់ចែងអនុវត្តអោយបានសំរេច ប្រកបដោយគតិ យុត្តិធម៌ ស្មើភាព សំដៅរក្សាអោយបាននូវសុក្រឹតភាព និង តម្លៃ នៃគ្រឿងឥស្សរិយយសរបស់ជាតិយើង ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០២

ស ខេង

**<u>ចម្លងជូន</u>**

- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ខុទ្ទកាល័យនាយករដ្ឋមន្ត្រី*
- *រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ*

*(ដើម្បីជូនជ្រាបជាព័ត៌មាន)*

- *អគ្គលេខាធិការដ្ឋាន*
- *អគ្គនាយកដ្ឋានរដ្ឋបាល*
- *អគ្គាធិការដ្ឋាន*
- *គ្រប់នាយកដ្ឋាន ចំណុះអគ្គនាយកដ្ឋានរដ្ឋបាល*
- *គ្រប់ខេត្ត ក្រុង*

*(ដើម្បីអនុវត្ត)*

- *ឯកសារ- កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ

.......................................

## ព្រឹត្តិប័ត្រពិន្ទុ និងមូលវិចារណ៍

### សំរាប់ធ្វើជាមូលដ្ឋាន ក្នុងការស្នើសុំប័ណ្ណសរសើរ និងគ្រឿងឥស្សរិយយស

## I. ជីវប្រវត្តិផ្ទាល់ខ្លួន

- នាមត្រកូល និងនាមខ្លួន:....................ជាអក្សរឡាតាំង:....................ភេទ:..........
- ថ្ងៃខែឆ្នាំកំណើត:........................................អត្តលេខ:........................................
- ឋានន្តរសក្តិ:....................ថ្នាក់លេខ:..........នៃក្របខ័ណ្ឌ:....................
- មុខតំណែងបច្ចុប្បន្ន:................................................................................
- អង្គភាព:................................................................................
- ថ្ងៃខែឆ្នាំ ដែលបានទទួលប័ណ្ណសរសើរចុងក្រោយ:........................................
- ថ្ងៃខែឆ្នាំ ដែលបានទទួលគ្រឿងឥស្សរិយយសចុងក្រោយ:........................................

*ធ្វើនៅ....................ថ្ងៃទី..........ខែ..........ឆ្នាំ..........*

**ហត្ថលេខាសាមីខ្លួន**

## II. ការវាយតំលៃដាក់ពិន្ទុ

១-មានសីលធម៌រស់នៅស្អាតស្អំ មិនប្រព្រឹត្តិអំពើពុករលួយ និងសកម្មភាពផ្ទុយពីច្បាប់រដ្ឋ

- អាកប្បកិរិយា (ពិន្ទុអតិបរមា ១ពិន្ទុ).................... [ ]
- សីលធម៌ (ពិន្ទុអតិបរមា ១ពិន្ទុ).................... [ ]

២-គំនិតផ្តួចផ្តើម និងមនសិការវិជ្ជាជីវៈខ្ពស់ សកម្មការងារ ឧស្សាហ៍ព្យាយាម ច្នៃប្រឌិត និងទទួលខុសត្រូវ

- មនសិការវិជ្ជាជីវៈ (ពិន្ទុអតិបរមា ២ពិន្ទុ).................... [ ]
- អព្យាក្រឹតភាព (ពិន្ទុអតិបរមា ២ពិន្ទុ).................... [ ]
- ការគោរពវិន័យ (ពិន្ទុអតិបរមា ២ពិន្ទុ).................... [ ]
- ការចាត់តាំង (ពិន្ទុអតិបរមា ២ពិន្ទុ).................... [ ]

៣-សមត្ថភាពបំពេញការងារ (ពិន្ទុអតិបរមា ៤ពិន្ទុ)........................................ [ ]

៤-សាមគ្គីភាព និងទំនាក់ទំនងល្អជាមួយមហាជន

- ទំនាក់ទំនងជាមួយមន្ត្រីរាជការ (ពិន្ទុអតិបរមា ២ពិន្ទុ)........................................ [ ]

-ទំនាក់ទំនងជាមួយប្រជារាស្ត្រ (ពិន្ទុអតិបរមា ២ពិន្ទុ)........................................ [ ]

៥-មានស្មារតីស្នេហាជាតិ គិតគូរដល់ផលប្រយោជន៍ជាតិ និងកិត្តិយសរបស់ក្រសួង (ពិន្ទុអតិបរមា ២ពិន្ទុ).. [ ]

ពិន្ទុសរុប :

<u>មូលវិចារណ៍</u>:..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

ធ្វើនៅ............... ថ្ងៃទី........ ខែ........... ឆ្នាំ..............

**ប្រធានអង្គភាព**